# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 486

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : សិក្ខាសាលាស្តីពីការបញ្ជ្រាបព័ត៌មានគន្លឹះពាក់ព័ន្ធនឹង «អាស៊ានឆ្នាំ២០២៥៖ ដំណើរឆ្ពោះទៅមុខរួមគ្នា»

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 02/01/17

កាលបរិច្ឆេទបញ្ចប់គម្រោង 29/12/17

៣. ចំណាយគម្រោងសរុប $12,500

៤. ស្ថាប័នទទួលខុសត្រូវ ទីស្តីការគណៈរដ្ឋមន្ត្រី

RESPONSIBLE UNIT

អង្គភាពទទួលខុសត្រូវ

៥. ស្ថានភាពគម្រោង គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ថវិកាជាតិ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងស្នើនេះនឹងគូសបញ្ជាក់ពីការប្តេជ្ញារបស់កម្ពុជា ក្នុងការបន្តធ្វើសមាហរណកម្មក្នុងតំបន់អាស៊ានឱ្យស៊ីជម្រៅ តាមរយៈការចែករំលែកនូវធាតុផ្សំគន្លឹះ បញ្ហាប្រឈម និងកាលានុវត្តភាពនៃ «អាស៊ានឆ្នាំ ២០២៥៖ ដំណើរឆ្ពោះទៅមុខរួមគ្នា» ដែលឯកសារនេះដើរតួជាផែនទីចង្អុលផ្លូវរបស់អាស៊ាន ក្នុងរយៈពេលមួយទសវត្សរ៍នេះ (ឆ្នាំ២០១៦-២០២៥) និងតាមរយៈការបង្កើនការយល់ដឹងរបស់មន្ត្រីបច្ចេកទេស ដែលតំណាងអង្គភាព ស្ថាប័ន និងនាយកដ្ឋាននានា ចំណុះទីស្តីការគណៈរដ្ឋមន្ត្រី។ គម្រោងស្នើនេះ នឹងកត់សម្គាល់នូវយុទ្ធសាស្ត្រនានា ដើម្បីទាញយកអត្ថប្រយោជន៍ពីដំណើរការសហគមន៍អាស៊ានក្រោយឆ្នាំ២០១៥។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍនវិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

អភិបាលកិច្ច និងរដ្ឋបាល

**១២. ទីតាំងអនុវត្តគម្រោង** (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

រាជធានីភ្នំពេញ,

**១៣. គោលបំណងរបស់គម្រោង** (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គម្រោងស្នើនេះ មានគោលបំណងសម្រេចឱ្យបាននូវ៖ (១) ការបង្កើនការយល់ដឹងរបស់មន្ត្រីបច្ចេកទេសនៃទីស្តីការគណៈរដ្ឋមន្ត្រី ពាក់ព័ន្ធនឹងធាតុផ្សំគន្លឹះ បញ្ហាប្រឈម និងកាលានុវត្តភាពនៃ «អាស៊ានឆ្នាំ២០២៥៖ ដំណើរឆ្ពោះទៅមុខរួមគ្នា» និង (២) ការបង្កើតយុទ្ធសាស្ត្រ ដើម្បីធានាឱ្យបានអ្នកចូលរួមយល់ដឹងពី «អាស៊ានឆ្នាំ២០២៥៖ ដំណើរឆ្ពោះទៅមុខរួមគ្នា» ដែលជាផែនទីចង្អុលផ្លូវអាស៊ានសម្រាប់រយៈពេលមួយទសវត្សរ៍នេះ ឆ្នាំ២០១៦ ដល់ឆ្នាំ២០២៥។ ចំណុចសំខាន់មួយទៀត គឺថាកម្ពុជាជាប្រទេសសមាជិកអាស៊ាន។ បន្ថែមពីលើនេះ សកម្មភាពស្នើនេះ នឹងគូសបញ្ជាក់ពីការប្តេជ្ញារបស់កម្ពុជាក្នុងការធ្វើសមាហរណកម្មឱ្យស៊ីជម្រៅបន្ថែមទៀតទៅក្នុងតំបន់អាស៊ាន។

**១៤. ការពិពណ៌នាអំពីគម្រោង** (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

ដោយសារថាអាស៊ានទើបសម្រេចបានសហគមន៍របស់ខ្លួនជាស្ថាពរ នៅចុងឆ្នាំ២០១៥ ប្រមុខរដ្ឋអាស៊ានបានអនុម័ត «អាស៊ានឆ្នាំ២០២៥៖ ដំណើរឆ្ពោះទៅមុខរួមគ្នា» ដែលជាឯកសារប្រកបដោយសារសំខាន់របស់អាស៊ាន ដើម្បីកំណត់ទិសដៅឆ្ពោះទៅមុខរបស់អាស៊ានក្នុងរយៈពេលមួយទសវត្សរ៍នេះ (២០១៦-២០២៥)។ ក្នុងនាមជាប្រទេសសមាជិកអាស៊ាន កម្ពុជាក៏ត្រូវចូលរួមជាមួយបណ្តាប្រទេសសមាជិកដទៃទៀត ដើម្បីផ្សព្វផ្សាយ និងបញ្ជ្រាបឯកសារដ៏មានសារសំខាន់នេះ ជូនចំពោះប្រជាពលរដ្ឋខ្លួន ជាពិសេសមន្ត្រីបច្ចេកទេស។ ក្នុងន័យនេះ គម្រោងស្នើនេះត្រូវបានគ្រោងនឹងអនុវត្តក្នុងឆ្នាំ២០១៧ ហើយអ្នកចូលរួមគឺមន្ត្រីបច្ចេកទេស ដែលចាត់បញ្ជូនដោយអង្គភាព ស្ថាប័ន និងនាយកដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី។

ដូចបានបញ្ជាក់ក្នុងកម្មវត្ថុ គម្រោងស្នើនេះជាវិធីមួយ ដើម្បីបង្កើនការយល់ដឹងរបស់មន្ត្រីបច្ចេកទេសពីធាតុផ្សំគន្លឹះ បញ្ហាប្រឈម និងកាលានុវត្តភាពនៃសហគមន៍អាស៊ានក្រោយឆ្នាំ២០១៥ ជាអាទិ៍ «អាស៊ានឆ្នាំ២០២៥៖ ដំណើរឆ្ពោះទៅមុខរួមគ្នា»។ បន្ថែមពីលើនេះ គម្រោងស្នើនេះ នឹងកត់សម្គាល់ពីយុទ្ធសាស្រ្តដើម្បីទាញយកអត្ថប្រយោជន៍ពីសហគមន៍អាស៊ាន ជាពិសេសសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)។

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ជាបឋម ដោយសារកម្ពុជាជារដ្ឋសមាជិកអាស៊ាន ហើយសហគមន៍អាស៊ានទើបត្រូវបានបង្កើតឡើងនាចុងឆ្នាំ២០១៥កន្លងទៅនេះ ដូច្នេះវាចាំបាច់ណាស់ក្នុងការចែករំលែក និងផ្សព្វផ្សាយនូវធាតុផ្សំគន្លឹះ បញ្ហាប្រឈម និងកាលានុវត្តភាពនៃ «អាស៊ានឆ្នាំ២០២៥៖ ដំណើរឆ្ពោះទៅមុខរួមគ្នា»។ ការបង្កើនការយល់ដឹងពីសហគមន៍អាស៊ាន ជាពិសេសការប្តេជ្ញាដែលបានកំណត់ដោយប្រមុខរដ្ឋអាស៊ាន នឹងផ្តល់សារៈសំខាន់ឱ្យអ្នកចូលរួម និងបណ្តាភាគីពាក់ព័ន្ធ អាចត្រៀមលក្ខណៈ និងទាញយកអត្ថប្រយោជន៍ពីសហគមន៍អាស៊ាននេះ។ ទីពីរ គម្រោងស្នើនេះរួមមានសមាសភាព ដូចជា វាគ្មិន/អ្នកជំនាញមកពីក្រសួងនិងស្ថាប័នពាក់ព័ន្ធនានា ជាអាទិ៍ តំណាងមកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចែករំលែកការយល់ដឹង ការអនុវត្តន៍ល្អៗ និងបញ្ហាប្រឈមពាក់ព័ន្ធនឹងសហគមន៍អាស៊ាន។

ជាចុងបញ្ចប់ របាយការណ៍សង្ខេបនឹងត្រូវបានចងក្រងនិងផ្សព្វផ្សាយ ទាំងជាភាសាខ្មែរនិងអង់គ្លេស។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

គម្រោងស្នើនេះ នឹងផ្ដល់អត្ថប្រយោជន៍ដល់ទាំងអ្នកចូលរួម (មន្ត្រីបច្ចេកទេសរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី) និងបណ្ដាភាគីពាក់ព័ន្ធ រួមទាំងវិស័យរដ្ឋនិងឯកជន។ បន្ថែមពីលើនេះ អ្នកទទួលបានអត្ថប្រយោជន៍ផ្ទាល់ពីគម្រោងនេះ គឺអ្នកចូលរួម វាគ្មិន និងបុគ្គលដែលរួមចំណែកក្នុងគម្រោងនេះ។ មួយវិញទៀត គម្រោងនេះនឹងផ្ដល់អត្ថប្រយោជន៍ដោយប្រយោលដល់ភាគីដែលមានចំណាប់អារម្មណ៍លើដំណើរការសហគមន៍អាស៊ាន ក្រោយឆ្នាំ២០១៥។ បន្ទាប់ពីទទួលបានចំណេះដឹង និងបទពិសោធន៍ពីគម្រោងនេះ អ្នកចូលរួមអាចយកចំណេះដឹង និងបទពិសោធន៍ទៅអនុវត្ត។ គម្រោងនេះនឹងរួមចំណែកដោយប្រយោលចំពោះកំណើនសេដ្ឋកិច្ចជាតិ ហើយប្រទេសសមាជិកអាស៊ានដទៃទៀត អាចទទួលបានអត្ថប្រយោជន៍ពីលទ្ធផលនៃរបាយការណ៍របស់គម្រោងនេះដោយប្រយោល។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទានចាប់ផ្ដើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

ដូចមានចែងក្នុងយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ការបន្តចូលរួមរបស់កម្ពុជាក្នុងសមាហរណកម្មតំបន់ (ចំណុច ២.៤) និងការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស (ចំណុច ៦.២) ជាកត្តាអាទិភាពដែលគម្រោងនេះផ្ដោតលើ ដែលកត្តាទាំងនេះ មិនត្រឹមតែចូលរួមកាត់បន្ថយភាពក្រីក្រ តែថែមទាំងរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិផងដែរ ជាអាទិ៍ តាមរយៈការលើកកម្ពស់ការយល់ដឹងពីជាតុផ្សំ បញ្ហាប្រឈម និងកាលានុវត្តភាពនៃសហគមន៍អាស៊ានក្រោយឆ្នាំ២០១៥ និងការស្វែងយល់ពីយុទ្ធសាស្រ្តដើម្បីទទួលបានអត្ថប្រយោជន៍ពីសហគមន៍នេះ។ មួយវិញទៀត គម្រោងស្នើនេះ នឹងបង្ហាញពីការប្ដេជ្ញារបស់កម្ពុជា ក្នុងសមាហរណកម្មតំបន់ឱ្យស៊ីជម្រៅបន្ថែមទៀត។

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្ដេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

គម្រោងស្នើនេះ បានគិតគូពីសារសំខាន់នៃសមភាពយេនឌ័រ ដែលវិស័យអាទិភាពមួយនៃយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ ដែលជាលទ្ធផល សមភាពយេនឌ័រនឹងត្រូវបានអនុវត្តនៅពេលជ្រើសរើសអ្នកចូលរួម ដើម្បីធានាឱ្យបាននូវតុល្យភាពរវាងស្ត្រីនិងបុរស។

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

នាយកដ្ឋានអាស៊ាននៃទីស្តីការគណៈរដ្ឋមន្ត្រី មានការិយាល័យសម្រួលគម្រោងអាស៊ាន ដែលគម្រោងទាំងនោះស្នើឡើងដោយស្ថាប័ន និងអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី។ ផ្អែកលើបទពិសោធន៍ជាច្រើនឆ្នាំ នាយកដ្ឋានមានសមត្ថភាពពេញលេញនិងបទពិសោធន៍ ក្នុងការលើក សម្រេចសម្រួល និងអនុវត្តគម្រោងនានា ជាពិសេសគម្រោងថ្នាក់តំបន់។

២៣. ស្ថិរភាពនៃការអនុវត្តគម្រោង (ពណ៌នាសង្ខេបអំពីវិធានការពារមិនឱ្យគម្រោងនឹងមិនជួបប្រទះភាពប្រឈមនានា ដែលបណ្តាលឱ្យមាន ការយឺតយ៉ាវពេលក្នុងការអនុវត្តគម្រោង។)

មិនមាន

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

គម្រោងនេះត្រូវបានស្នើឡើងដោយផ្អែកលើការប្រើប្រាស់ថវិការដ្ឋ។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2017 | | 2018 | 2019 | 2020 | 2021 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2019-2021 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 12.5 | 0.0 | 0.0 | 12.5 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 12.5 | 0.0 | 0.0 | 12.5 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 12.5 | 0.0 | 0.0 | 12.5 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2017 | | 2018 | 2019 | 2020 | 2021 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2019-2021 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 12.5 | 0.0 | 0.0 | 12.5 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 12.5 | 0.0 | 0.0 | 12.5 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 12.5 | 0.0 | 0.0 | 12.5 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: